**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ០១២/១៩ ក.ប/ស.ជ.ណ.ម.ហ

# សេចក្តីជូនដំណឹង
# ស្តីពី
# បណ្ណការងារ និងសៀវភៅការងារជនបរទេស (ទម្រង់ថ្មី)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតជនបរទេស ដែលស្ថិតនៅក្នុងដែនអនុវត្តច្បាប់ស្តីពីការងារទាំងអស់បានជ្រាបថា កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ កន្លងទៅនេះ ក្រសួងបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីបន្ថយនីតិវិធីរដ្ឋបាល ផ្តល់សេវាងាយស្រួល និងឆាប់រហ័ស ព្រមទាំងលុបបំបាត់ការចំណាយក្រៅផ្លូវការប្រកបដោយប្រសិទ្ធភាព ដោយបានទទួលការគាំទ្រជាច្រើនពីសំណាក់សាធារណជន។

ជាមួយគ្នានេះ ដើម្បីបង្ការការក្លែងបន្លំនានា ក្រសួងគ្រោងនឹងដាក់ប្រើប្រាស់នូវបណ្ណ/សៀវភៅការងារជនបរទេសទម្រង់ថ្មី ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០១៩ នេះតទៅ ដែលមានលក្ខណៈ ពិសេសដូចក្នុងឧបសម្ព័ន្ធជូនភ្ជាប់ជាមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតជនបរទេស ដែលស្ថិតនៅក្នុងដែនអនុវត្តច្បាប់ស្តីពីការងារទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៩
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

ឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងលេខ ០១២/១៩ ក.ប/ស.ជ.ណ.ម.ហ ចុះថ្ងៃ អង្គារ ១១ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២




បង្កប់ពន្លឺ UV សុវត្ថិភាព
ជាស្លាកសញ្ញាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ប្រើប្រាស់នូវបន្ទាត់សុវត្ថិភាពដើម្បីការពារក្លែងបន្លំ







ប្រើប្រាស់នូវពណ៌ OVI ចំណាំងផ្លាត

QR Code ផ្ទៀងផ្ទាត់ទិន្នន័យ

ឈ្មោះគេហទំព័ររក្សាទុកទិន្នន័យលើ QR Code